*Kampuchean Action for Primary Education*

# អង្គការសកម្មភាពសំរាប់បឋមសិក្សានៅកម្ពុជា

ឯកសារយោង

# ការបង្កើតការប្រើប្រាស់បណ្ណាល័យសំរាប់កុមារ

( សេចក្តីព្រាង )

កំពង់ចាម , ខែ ៦ ២០០៣

ឧបត្ថម្ភគាំទ្រដោយអង្គការ យូនីសេហ្វ / ស៊ីដា

# ការបង្កើតការប្រើប្រាស់បណ្ណាល័យសំរាប់កុមារ

## I. សេចក្តីផ្តើម :

ឯកសារនេះ រៀបរាប់អំពីលំនាំ ដែលគ្រូអាចអនុវត្តតាមដើម្បីបំផុសចំណាប់អារម្មណ៍ក្នុងការអាន និង ការប្រើប្រាស់បណ្ណាល័យ ។ អ្នកសំរបសំរួល កម្មវិធីសាលាកុមារមេត្រី អាចប្រើប្រាស់ឯកសារនេះ ដើម្បីរៀបចំតំរង់ទិសសំរាប់បណ្ណារក្ស និង គ្រូប្រចាំថ្នាក់ ។

## II. គោលបំណង :

- មានការប្រើប្រាស់បណ្ណាល័យ កាន់តែកើនឡើងដោយបង្កើនចំនួនសកម្មភាព និង ឯកសារបន្ថែម ។
- សិស្សពង្រឹងបំនិនក្នុងការអាន និង ចេះអាន ដោយឯករាជ្យ និង មានទំនុកចិត្តក្នុងខ្លួន ។

## III. រយៈពេល :

២ ម៉ោង ក្នុងការប្រជុំបច្ចេកទេសថ្ងៃព្រហស្បតិ៍ ។

## IV. ធនធានសំភារៈ :

- ក្រដាសផ្ទាំងធំ ។
- ប៊ិចហ្វឺត ។
- ស្កុត ។
- ឯកសារចែកជូន : ករណីសិក្សាស្តីពីបញ្ហាក្នុងបណ្ណាល័យ ។

## V. លំនាំបង្រៀន :

### 1. ការពង្រឹងបរិស្ថានរៀនសូត្រ ចិត្ត-សង្គមក្នុងបណ្ណាល័យ :

- អ្នកសំរបសំរួល អោយសិក្ខាកាមជាក្រុមតូច បញ្ចេញនូវគំនិតយោបល់ ដើម្បីកែលំអបណ្ណាល័យក្នុងសាលា ។ សិក្ខាកាម គួរតែប្រើតារាងដូចខាងក្រោម ។ មានគំនិតយោបល់មួយចំនួនក្នុងតារាង ក៏ប៉ុន្តែសិក្ខាកាមត្រូវតែបន្ថែមគំនិតយោបល់ខ្លះទៀតក្នុងតារាង ។ អ្នកសំរបសំរួល គួរតែរំលឹកសិក្ខាកាមថា ធនធាន និង ពេលវេលារបស់គេមានកំរិត ។ ដូច្នេះ គួរតែវាស់តំលៃនៃសកម្មភាពក្នុងបណ្ណាល័យដោយគិតដល់ឥទ្ធិពលលើការរៀនសូត្ររបស់សិស្សជាជាងគិតអំពីទិដ្ឋភាពល្អក្នុងបណ្ណាល័យ ។

| ការកែលំអបរិស្ថានចិត្តសង្គម រៀនសូត្រក្នុងបណ្ណាល័យ | លទ្ធផលរំពឹងទុកជាមុន ក្នុងការរៀនសូត្ររបស់សិស្ស | សកម្មភាពបន្តពង្រឹង | ធនធាន | អាចចាប់ផ្តើមអនុវត្តនៅពេលណា |
|---|---|---|---|---|
| ការបិទតាំងសុភាសិត | | | | |
| ការបិទតាំងរូបភាពសិក្សា | | | | |
| ការបិទតាំងស្នាដៃនិងរូបភាពសិស្ស | | | | |
| ការបិទតាំងផែនទីផ្សេង ៗ | | | | |
| ជ្រុងទុកដាក់សំបុត្រ | | | | |
| សំនួរប្រចាំសប្តាហ៍ | | | | |
| ល្បែងសិក្សា | | | | |
| ការបិទតាំងរូបភាពនិងរូបថត | | | | |
| ការប្រកួតប្រជែងក្នុងការប្រកបពាក្យ | | | | |

## 2. ការកំណត់ដំណោះស្រាយបញ្ហាផ្សេង ៗ :

- អ្នកសំរបសំរួល បែងចែកឯកសារស្តីអំពីបញ្ហាដែលធ្លាប់កើតមានឡើងនៅក្នុងបណ្ណាល័យភាគច្រើន ។ អោយសិក្ខាកាមពិភាក្សា ករណីសិក្សាទាំងនេះជាក្រុមតូច ដោយអោយគេជួយរកដំណោះស្រាយ ឬ កំណត់វិធានការកុំអោយបញ្ហាកើតមានឡើង ។ បន្ទាប់មកអោយក្រុមនីមួយ ៗ បង្ហាញពីចំលើយរបស់គេ ។

### ករណីសិក្សា

- បណ្ណាល័យត្រូវបិទទ្វារពេលម៉ោងសិក្សា សិស្សមិនអាចចូលអានក្នុងពេលចេញលេង ។
- បណ្ណារក្សធ្វើការតែមួយពេលព្រឹក ឬ មួយពេលល្ងាច ។ ដូច្នេះបណ្ណាល័យត្រូវស្មុះសេវាកម្មមួយពេលក្នុងមួយថ្ងៃ ។
- ក្រោយពីការពង្រាយគ្រូ គឺបណ្ណាល័យគ្មានបណ្ណារក្ស ។
- គ្មានអ្នកទទួលខុសត្រូវក្នុងបណ្ណាល័យ លើការងារចុះបញ្ជីសារពើភ័ណ និង ជួសជុលសៀវភៅរហែក ។
- ហិបចល័តគ្មានដំណើរការល្អ ។
- បណ្ណារក្សមិនយល់ពីការប្រមូលស្ថិតិក្នុងបណ្ណាល័យ ។
- សិស្សថ្នាក់ទី ១ ចូលបណ្ណាល័យ ហើយចេញយ៉ាងប្រញាប់ដោយសារគ្មានសកម្មភាពពិសេសសំរាប់គេ ។

- សិស្សមួយចំនួនតូចប្រើបណ្ណាល័យយ៉ាងញឹកញាប់ ។ សិស្សផ្សេងទៀតចូលបណ្ណាល័យ ១ ឬ ២ ដង ក្នុងមួយខែ ។ ប៉ុន្តែមានសិស្សមួយចំនួនតូចមិនដែលចូលបណ្ណាល័យ ។
- សិស្សថ្នាក់ទី ៥ និង ថ្នាក់ទី ៦ មិនចាប់អារម្មណ៍បន្តទៀតក្នុងបណ្ណាល័យ ដោយគេធ្លាប់អានសៀវភៅទាំងអស់នេះហើយ ។

## 3. <u>ការរៀបចំជ្រុងបណ្ណាល័យក្នុងថ្នាក់រៀន</u> :

- ការប្រើប្រាស់ជ្រុងបណ្ណាល័យ នៅក្នុងថ្នាក់រៀនអាចបង្កើនការអាន សរសេរ របស់កុមារកាន់តែប្រសើរឡើង ។
- គ្រូគួរតែពិចារណាលើសកម្មភាពដូចខាងក្រោមក្នុងការរៀបចំជ្រុងបណ្ណាល័យ ÷
    1. នៅក្នុងជ្រុងបណ្ណាល័យមានសៀវភៅអានសំរាប់កុមារ ។
    2. គ្រូត្រូវតែ ផ្លាស់ប្តូរសៀវភៅថ្មីអោយបានញឹកញាប់ និង ទៀងទាត់ ។
    3. គ្រូគួរតែយល់ដឹងអំពីការជ្រើសរើសសៀវភៅទៅតាមកំរិតនៃការយល់ដឹងរបស់កុមារ ។ ឧទាហរណ៍ មិនគួរដាក់ សៀវភៅគ្មានរូបភាពក្នុងជ្រុងបណ្ណាល័យនៅថ្នាក់ទី ១ ឬ ទី ២ ។ ប្រសិនជាគ្រូមិនសូវយល់ថា តើសៀវភៅណាមួយមានលក្ខណៈសមស្របសំរាប់កុមារ គ្រូគួរតែអោយសិស្ស ២ ឬ ៣ នាក់ សាកល្បងអានទំព័រមួយក្នុងសៀវភៅ មុននិងដាក់សៀវភៅក្នុងជ្រុងបណ្ណាល័យ ។ ប្រសិនជាសិស្សជួបការលំបាកក្នុងការអានសៀវភៅនេះ គ្រូគួរតែជ្រើសរើសសៀវភៅណាដែលស្រួលអានជាង ។ ចំពោះសិស្សណារៀនយឺត ឬ រៀន លឿនយើងគួរតែជ្រើសរើសសៀវភៅណាដែលពួកគេចាប់អារម្មណ៍ ។
    4. វាជារឿងមួយដ៏សំខាន់ដែលកុមារអាចយល់នូវអ្វីដែលពួកគេបានអាន ។ ហេតុដូច្នេះហើយទំរង់សំរាប់អានសៀវភៅត្រូវបានដាក់នៅជ្រុងបណ្ណាល័យ ។ គ្រូត្រូវតែធ្វើការពន្យល់ដល់កុមារនូវរបៀបបំពេញទំរង់នោះ ។
    5. បន្ទាប់ពីអានសៀវភៅរួច កុមារត្រូវតែបំពេញទំរង់សំរាប់អានសៀវភៅ ។ នៅពេលដែលបញ្ចប់ការបំពេញទំរង់រួច កុមារត្រូវតែយកទំរង់របស់គេទៅទុកនៅជ្រុងបណ្ណាល័យ កុមារអាចអានទំរង់ទាំងនោះនិង ជ្រើសរើសសៀវភៅផ្អែកទៅលើអ្វីដែលសិស្សផ្សេងទៀតបានសរសេរ ។
    6. គ្រូប្រចាំថ្នាក់ ឬ បណ្ណារក្សអាចដាក់សំនួរអោយសិស្សស្រាវជ្រាវដែលគេហៅថា " សំនួរប្រចាំសប្តាហ៍ " ឬ " សំនួរប្រចាំថ្ងៃ " ។ អាចបិទសំនួរនេះលើជញ្ជាំង ហើយសិស្សអាចធ្វើការស្រាវជ្រាវរយៈពេលមួយសប្តាហ៍ ឬ មួយថ្ងៃ ដើម្បីរកចំលើយ ។ សិស្សធ្វើការស្រាវជ្រាវនេះដោយពិនិត្យមើលសៀវភៅក្នុងជ្រុងបណ្ណាល័យក្នុងថ្នាក់របស់គេ ឬ ក្នុងបណ្ណាល័យសាលារៀន ។ ម្យ៉ាងទៀតសិស្សអាច

ស្រាវជ្រាវដោយពិនិត្យ មើលរូបភាពសិក្សា ឬ ផែនទីផ្សេង ៗ ដែលបិទលើជញ្ជាំងក្នុងបណ្ណាល័យ ។

7. សំបុត្រដែលផ្ញើពីកំរងផ្សេងទៀត : អាចប្រមូលសំបុត្រដែលបានផ្ញើពីសិស្សតាមកំរងផ្សេង ៗ ទៀត ថែរក្សាទុកក្នុងបណ្ណាល័យ ។ ដើម្បីជួយសិស្ស សរសេរសំបុត្រ គួរតែមានសេចក្តីណែនាំអំពីការសរសេរសំបុត្រក្នុងជ្រុងបណ្ណាល័យ ។

## 4. ការបង្កើនចំនួនឯកសារសំរាប់អានក្នុងបណ្ណាល័យ :

អ្នកសំរបសំរួល គួរតែលើកបញ្ហាថា បណ្ណាល័យភាគច្រើនមិនមានលទ្ធភាពផ្តល់សៀវភៅថ្មីបន្ថែមសំរាប់សិស្សយ៉ាងញឹកញាប់ ។ អ្នកសំរបសំរួល សុំអោយសិក្ខាកាមរកនឹកមធ្យោបាយផ្សេង ៗ ដើម្បីបង្កើនឯកសារបន្ថែមក្នុងបណ្ណាល័យ ។ គួរតែមានសរសេរគំនិតយោបល់ទាំងអស់លើក្តារខៀន ។ បំផុសគំនិតយោបល់របស់សិក្ខាកាមមុននឹងបង្ហាញគំនិតយោបល់ដូចខាងក្រោមនេះ ÷

- ប្រមូលកាសែតចាស់ ៗ ពីសហគមន៍ ។
- ប្រមូលទស្សនាវដ្តីចាស់ ៗ ពីសហគមន៍ ។
- ចងក្រងសំបុត្រដែលត្រូវបានទទួលពីសិស្សក្នុងសាលាផ្សេង ៗ ។ បង្កើតជា « សៀវភៅសំបុត្រពីមិត្តភ័ក្ត » ។
- ចងក្រងស្នាដៃដែលដកស្រង់ចេញពីសីមីស្នាដៃសិស្សម្នាក់ ៗ ក្នុងថ្នាក់បង្កើតជា « សៀវភៅស្នាដៃរបស់ថ្នាក់ទី ៥ . . . ។ល ។ » ។ អាចរៀបចំជាសៀវភៅធំដោយប្រើប្រាស់ស្នាដៃរបស់សិស្សដែលរៀននៅក្នុងឆ្នាំសិក្សាមុន ៗ ។
- ការបិទតាំងលទ្ធផលនៃគំរោងស្រាវជ្រាវ ដូចជា ស្រាវជ្រាវអំពីប្រវត្តិសាស្ត្រក្នុងមូលដ្ឋាន ។
- ចងក្រងលទ្ធផលនៃការជំទាស់ដែលសិស្សបានធ្វើជាមួយសមាជិកសមាគម ( ចូរអានឯកសារស្តីអំពី « ជនគំរូ » « ប្រធានបទគំរោងស្រាវជ្រាវ » «ស្រាវជ្រាវអំពីប្រវត្តិសាស្ត្រក្នុងមូលដ្ឋាន » បង្កើតជា «សៀវភៅសម្ភាសន៍ជាមួយប្រជាជនក្នុងមូលដ្ឋាន » ។
- ប្រមូលពត៌មានស្រាវជ្រាវដោយសិស្សនៅក្នុងថ្នាក់ផ្សេង ៗ ចងក្រងបង្កើតជាសៀវភៅពត៌មានប្រចាំខែ ។ ឧទាហរណ៍ : « ពត៌មានក្នុងមូលដ្ឋានប្រចាំខែតុលា ២០០៣ » « ពត៌មានថ្នាក់ជាតិ ខែ វិច្ឆិកា ២០០៣ » « ពត៌មានអន្តរជាតិ ខែ មករា ២០០៤ » ។
- អោយសិក្ខាកាម ពិភាក្សាយ៉ាងស៊ីជំរៅអំពីរបៀបអនុវត្តគំនិតយោបល់នីមួយ ៗ ក្នុងស្ថាប័នជាក់ស្តែង ។ ក្នុង
- ការពិភាក្សាជាក្រុមតូច គួរតែពិចារណាលើសំនួរខាងក្រោមនេះ ÷
  - តើអ្នកណាទទួលខុសត្រូវក្នុងការរៀបចំសកម្មភាពនេះ ។
  - តើអ្នកណាទទួលខុសត្រូវត្រួតពិនិត្យភាពសមស្របរបស់កាសែត ឬ ទស្សនាវដ្តី ។

- ក្នុងសកម្មភាពចងក្រងស្នាដៃរបស់សិស្ស អ្នកណាទទួលខុសត្រូវ ត្រួតពិនិត្យ និង កែអក្ខរាវិរុទ្ធរបស់សិស្ស ។
- ប្រសិនជាសិក្ខាកាមពេញចិត្តសកម្មភាព តើសាលារៀនអាចចាប់ផ្តើមអនុវត្តនៅពេលណា ។
- តើសាលារៀនត្រូវតែអនុវត្តជំហានអ្វីខ្លះក្នុងសកម្មភាពនីមួយ ៗ មុននឹងឈានទៅជំហានផ្តល់ឯកសារបន្ថែមទៀតក្នុងបណ្ណាល័យ ?
- តើសាលារៀនត្រូវការធនធាន និង សំភារៈអ្វីខ្លះក្នុងការអនុវត្តសកម្មភាពទាំងនោះ ។

5. **ការជំរុញអោយកុមារ ឬ គ្រូ ឬ ប្រជាជន សរសេររឿងនិទាន** :

- ប្រសិនជាមានធនធានមនុស្សដែលចាប់អារម្មណ៍ក្នុងមូលដ្ឋាននោះជាការល្អប្រសើរមួយបើអ្នកនោះអាចសរសេរចងក្រងជារឿងនិទានបាន ។ យើងអាចរៀបចំជាសិក្ខាសាលាសំរាប់អ្នកទាំងនោះដោយប្រើប្រាស់មូលនិធិខ្លះ ៗ ពីអំណោយសំរាប់គំរោងលើសិក្ខាសាលានេះ ។